ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
លេខ : ០៤៩៩ សជណ.ទទក.ទប

# សេចក្ដីជូនដំណឹង
## ស្ដីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើសបុគ្គលិក ចំនួន ១១ រូប ដើម្បីចូលបម្រើការងារនៅ អគ្គិសនីខេត្តព្រះសីហនុ នៃអគ្គិសនីកម្ពុជា ដូចខាងក្រោម :

*- **លក្ខណៈសម្បត្តិបេក្ខជន** :
- បេក្ខជនទាំង ០២ ភេទ, ត្រូវមានអាយុចាប់ពី ១៨ ដល់ ៣៥ឆ្នាំ

១- បុគ្គលិកឃ្លាំងសម្ភារ ០១ រូប :
- បៀវត្សរ៍ផ្ដល់ជូន : បៀវត្សរ៍សុទ្ធ E.III.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90% = ១,១០៩,៣៤០ រៀល ឡើងទៅ
- កម្រិតវប្បធម៌ : ចាប់ពី សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel
- ភាសាអង់គ្លេស : ចេះ អាចប្រើការបាន

២- បុគ្គលិកគណនេយ្យ ០១ រូប :
- បៀវត្សរ៍ផ្ដល់ជូន : បៀវត្សរ៍សុទ្ធ E.III.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90% = ១,១០៩,៣៤០ រៀល ឡើងទៅ
- កម្រិតជំនាញ : ចាប់ពី បរិញ្ញាបត្រគណនេយ្យ ឡើងទៅ
- មានបទពិសោធន៍លើការងារគណនេយ្យយ៉ាងតិច ០១ ឆ្នាំ
- ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel
- ភាសាអង់គ្លេស : ចេះ អាចប្រើការបាន

៣- ភ្នាក់ងារដំឡើងជួសជុលនិងថែទាំបណ្ដាញ ០៧ រូប :
- បៀវត្សរ៍ផ្ដល់ជូន : បៀវត្សរ៍សុទ្ធ E.III.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90% = ១,១០៩,៣៤០ រៀល ឡើងទៅ
- កម្រិតជំនាញ : ចាប់ពី សញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនី ឡើងទៅ
- ភាសាអង់គ្លេស : ចេះ អាចប្រើការបាន ជាមធ្យម

៤- ភ្នាក់ងារស្រង់ថាមពល ០២រូប :
- បៀវត្សរ៍ផ្ដល់ជូន : បៀវត្សរ៍សុទ្ធ E.III.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90% = ១,១០៩,៣៤០ រៀល ឡើងទៅ
- កម្រិតវប្បធម៌ : ចាប់ពី សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឡើងទៅ
- ភាសាអង់គ្លេស : ចេះ អាចប្រើការបាន ជាមធ្យម ។

*- **បញ្ជាក់** : បេក្ខនារីគ្រប់ខេត្ត-ក្រុង និងបេក្ខជន ដែលមានអាសយដ្ឋានស្ថិតនៅខេត្តសាមី ប្រសិនបើលទ្ធផលពិន្ទុប្រហាក់ប្រហែលគ្នា គឺត្រូវផ្តល់អាទិភាព។

*- **បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ** :

- ពាក្យសុំចូលបម្រើការងារ មានបិទតែមប្រើ(១.០០០ រៀល) ចំនួន ០១ ច្បាប់
- ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ ចំនួន ០១ ច្បាប់
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬអាចយក សៀវភៅគ្រួសារ ឬអត្តសញ្ញាណប័ណ្ណ(ច្បាប់ចម្លង មានបញ្ជាក់ពី សាលារាជធានីភ្នំពេញ ឬសាលាខេត្ត) ឬលិខិតបញ្ជាក់ទីលំនៅ ចុះហត្ថលេខាពីខណ្ឌ-ស្រុក ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់កិរិយាមារយាទ ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់សុខភាព(ចេញដោយនាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ)ចំនួន ០១ ច្បាប់
- ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ មានបញ្ជាក់ពីសាលារាជធានីភ្នំពេញ ឬសាលាខេត្ត ចំនួន ០១ ច្បាប់
- តារាងពិន្ទុ (TRANSCRIPT) ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ ឬ ច្បាប់ចម្លងសញ្ញាប័ត្រផ្សេងៗ (បើមាន) ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ពីបទពិសោធន៍ការងារ (បើមាន) ចំនួន ០១ ច្បាប់

*- **ទីកន្លែងទទួលពាក្យ** : សាលប្រជុំអគារ C ជាន់ទី៣ នៃអគ្គិសនីកម្ពុជា

ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៤ រៀងរាល់ថ្ងៃធ្វើការ

- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០
- ពាក្យសុំចូលបម្រើការងារ ត្រូវប្រើប្រាស់គំរូ មានបោះត្រាសម្គាល់របស់ អគ្គិសនីកម្ពុជា ។

*- **ព័ត៌មានផ្សេងៗ** : សូមអញ្ជើញមកទាក់ទងការិយាល័យរដ្ឋបាល នៃទីស្នាក់ការកណ្តាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៨៧១ និង ០២៣ ៧២៤ ៧៧១ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤

**ក. ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

អគ្គនាយករង